**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសុខាភិបាល**

លេខ ៣៦៧ សបស/៥០៣៩

រាជធានីភ្នំពេញ, ថ្ងៃទី ៣០ ខែកក្កដា ឆ្នាំ២០០៧.

លិខិតចូល
ថ្ងៃទី ៣០ ខែ៧ ឆ្នាំ២០០៧

# ប្រកាស

## ស្តីពី

## ការផ្ទេរមន្ទីរពេទ្យបង្អែកថ្នាក់ខេត្ត-ក្រុង មកនៅក្រោមការគ្រប់គ្រងរបស់មន្ទីរសុខាភិបាលខេត្ត-ក្រុង

## រដ្ឋមន្ត្រីក្រសួងសុខាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកត ចុះថ្ងៃទី១៥-០៧-០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម នស/រកម/០១៩៦/០៦ ចុះថ្ងៃទី២៤-០១-៩៦ប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញអនុក្រឹតលេខ ៦៧អនក្រ-បក ចុះថ្ងៃទី២២-១០-៩៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសុខាភិបាល
- យោងតាមស្មារតីអង្គប្រជុំចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០០៧
- យោងតាមការចាំបាច់របស់ក្រសួងសុខាភិបាល

## សំរេច

**ប្រការ ១:** មន្ទីរពេទ្យបង្អែកសំណុំសកម្មភាពបង្គ្រប់កំរិត ៣ ឬ ២ ដែលមានទីតាំងនៅក្នុងទីរួមខេត្ត-ក្រុង ហើយបច្ចុប្បន្នស្ថិតនៅក្រោមការគ្រប់គ្រងរបស់ការិយាល័យសុខាភិបាលស្រុកប្រតិបត្តិត្រូវផ្ទេរ ឱ្យស្ថិតនៅក្រោមការគ្រប់គ្រងដោយផ្ទាល់របស់មន្ទីរសុខាភិបាលខេត្ត-ក្រុងវិញ និងមានឋានៈស្មើនឹង ការិយាល័យចំណុះមន្ទីរសុខាភិបាលខេត្ត-ក្រុងដែរ ។ ដូច្នេះ ការិយាល័យស្រុកប្រតិបត្តិដែលមានទីតាំងនៅទីរួមខេត្ត-ក្រុងនឹងទទួលខុសត្រូវគ្រប់គ្រងតែមណ្ឌលសុខភាពប៉ុណ្ណោះ ។

**ប្រការ ២:** មន្ទីរពេទ្យបង្អែកខេត្ត-ក្រុងដែលមានចែងក្នុងប្រការ១ ក្រៅពីមានតួនាទី និងមុខងារដូចមានចែងនៅក្នុង *សេចក្តីណែនាំស្តីពីសំណុំ សកម្មភាពបង្គ្រប់* ដែលបានដាក់ឱ្យប្រើប្រាស់ជាផ្លូវការដោយក្រសួងសុខាភិបាល កាលពីថ្ងៃទី១៥ ខែធ្នូ ឆ្នាំ ២០០៦ ត្រូវជួយលើកកំពស់គុណភាពសេវានៅមន្ទីរពេទ្យបង្អែក និងមណ្ឌល

សុខភាពផ្សេងៗទៀតតាមរយៈការចូលរួមក្នុងការបណ្តុះបណ្តាលនៅនឹងកន្លែង និងការចុះអភិបាលជាមួយក្រុមការងារអភិបាលនៃមន្ទីរសុខាភិបាលខេត្ត-ក្រុងក្នុងករណីចាំបាច់ ។

**ប្រការ ៣:** ការរៀបចំរចនាសម្ព័ន្ធដឹកនាំនិងគ្រប់គ្រង និងការប្រព្រឹត្តទៅរបស់មន្ទីរពេទ្យបង្អែកខេត្ត-ក្រុង ត្រូវអនុលោមតាម *សេចក្តីណែនាំស្តីអំពីសំណុំសកម្មភាពបង្គ្រប់* ។

**ប្រការ ៤:** ប្រធានមន្ទីរពេទ្យបង្អែកខេត្ត-ក្រុងដែលមានចែងក្នុងប្រការ១ នឹងលែងមានតួនាទីជាអនុប្រធានការិយាល័យសុខាភិបាលស្រុកប្រតិបត្តិនៅពេលដែលមន្ទីរពេទ្យបង្អែកនោះ ត្រូវបានសមាហរណកម្មពេញលេញទៅក្នុងរចនាសម្ព័ន្ធរបស់មន្ទីរសុខាភិបាលខេត្ត-ក្រុង ។

**ប្រការ ៥:** ប្រធានមន្ទីរពេទ្យបង្អែកខេត្ត-ក្រុងខាងលើ ត្រូវទទួលខុសត្រូវចំពោះមុខប្រធានមន្ទីរសុខាភិបាលខេត្ត-ក្រុង ក្នុងការដឹកនាំគ្រប់គ្រង និងកិច្ចដំណើរការនៃការផ្តល់សេវាសំណុំសកម្មភាពបង្គ្រប់មានគុណភាព និងប្រសិទ្ធភាពខ្ពស់ ។

**ប្រការ ៦:** សំណើសុំធនធានគ្រប់ប្រភេទ (ថវិការួមទាំងប្រាក់បៀវត្ស បុគ្គលិក ឱសថ-បរិក្ខាពេទ្យ សំភារៈផ្សេងៗទៀត....) ។ល។ ដើម្បីដំណើរការមុខងាររបស់មន្ទីរពេទ្យបង្អែកខេត្ត-ក្រុង និងការផ្គត់ផ្គង់ធនធានទាំងនោះ គឺនៅក្រោមការគ្រប់គ្រងរបស់មន្ទីរសុខាភិបាលខេត្ត-ក្រុង លើកលែងតែការផ្គត់ផ្គង់ឱសថ-បរិក្ខាពេទ្យ ដែលមន្ទីរពេទ្យបង្អែកខេត្ត-ក្រុងត្រូវទទួលដោយផ្ទាល់តាមរយៈប្រព័ន្ធចែកចាយរបស់ឃ្លាំងឱសថកណ្តាល ។

**ប្រការ ៧:** មន្ទីរពេទ្យបង្អែកខេត្ត-ក្រុងត្រូវរាយការណ៍និងធ្វើរបាយការណ៍មកមន្ទីរសុខាភិបាលខេត្ត-ក្រុង យោងទៅតាមបទដ្ឋាននិតិវិធី និងសេចក្តីណែនាំផ្សេងៗរបស់ក្រសួងសុខាភិបាល ។

**ប្រការ ៨:** ការបង់ប្រាក់ចំណូលដែលទទួលបានពីសេវាហិរញ្ញប្បទាន ៥ % នៃ ៦០ % ទៅឱ្យការិយាល័យសុខាភិបាលស្រុកប្រតិបត្តិ ដូចមានចែងនៅក្នុង *សេចក្តីណែនាំស្តីពីការគ្រប់គ្រងហិរញ្ញប្បទាន* របស់ក្រសួងសុខាភិបាល ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ ២០០៧ ត្រូវបានលើកលែងសំរាប់មន្ទីរពេទ្យខេត្ត-ក្រុងដូចមានចែងក្នុងប្រការ១ នៃប្រកាសនេះ ។

**ប្រការ ៩** បែបបទនៃផែនការនីយកម្មប្រចាំឆ្នាំរបស់មន្ទីរពេទ្យបង្អែកខេត្ត-ក្រុង ត្រូវសមាហរណកម្មទៅក្នុងបែបបទនៃផែនការនីយកម្មប្រចាំឆ្នាំរបស់មន្ទីរសុខាភិបាលខេត្ត-ក្រុង ។ ក្នុងករណីនេះ ផែនការប្រតិបត្តិប្រចាំឆ្នាំរបស់មន្ទីរពេទ្យបង្អែកខេត្ត-ក្រុង ក៏ត្រូវតែសមាហរណកម្មទៅក្នុងផែនការប្រតិបត្តិប្រចាំឆ្នាំ និងផែនការវិកិលរបស់មន្ទីរសុខាភិបាលខេត្ត-ក្រុង ផងដែរ ។

**ប្រការ ១០:** ក្នុងរយៈពេលអន្តរកាលនៃការរៀបចំដើម្បីផ្ទេរការគ្រប់គ្រងមន្ទីរពេទ្យបង្អែកខេត្ត-ក្រុងពីការិយាល័យសុខាភិបាលស្រុកប្រតិបត្តិទៅមន្ទីរសុខាភិបាលខេត្ត-ក្រុង មន្ទីរសុខាភិបាលខេត្ត-ក្រុង ការិយាល័យស្រុកប្រតិបត្តិ និងមន្ទីរពេទ្យបង្អែកខេត្ត-ក្រុងត្រូវ :

- សហការគ្នាជិតស្និទ្ធក្នុងការរៀបចំផ្ទេរការគ្រប់គ្រងនេះ ដោយភាពរលូននិងមានប្រសិទ្ធភាពស្របតាមខ្លឹមសារនៃប្រកាសនេះ ដោយគិតចាប់ពីថ្ងៃដែលប្រកាសនេះចូលជាធរមានរហូតដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ ២០០៧ ដោយរក្សាការអនុវត្តនីតិវិធីរបៀបរបបការងារគ្រប់គ្រងនិងរដ្ឋបាលដែលកំពុងមានបច្ចុប្បន្ននៅដដែល នៅតាមមន្ទីរពេទ្យបង្អែកខេត្ត-ក្រុង ។

- អនុវត្តនីតិរបៀបរបបគ្រប់គ្រងរបស់មន្ទីរពេទ្យបង្អែកខេត្ត-ក្រុង ក្រោមចំណុះមន្ទីរសុខាភិបាលខេត្ត-ក្រុង ចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ ២០០៨ តទៅ ពោលគឺនៅពេលចាប់ផ្តើមអនុវត្តថវិកាឆ្នាំ២០០៨ និងបែបបទផែនការនីយកម្មវិស័យសុខាភិបាល ឆ្នាំ២០០៨ ។

**ប្រការ ១១:** អគ្គនាយកដ្ឋានបច្ចេកទេស និងអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ ព្រមទាំងនាយកដ្ឋាន និងអង្គភាពសុខាភិបាលចំណុះទីស្តីការក្រសួងសុខាភិបាល ត្រូវផ្តល់ការគាំទ្រចាំបាច់នានាដល់មន្ទីរសុខាភិបាលខេត្ត-ក្រុង និងស្រុកប្រតិបត្តិនៅក្នុងដំណើរការផ្ទេរការគ្រប់គ្រងមន្ទីពេទ្យបង្អែកខេត្ត-ក្រុង ពីការិយាល័យសុខាភិបាលស្រុកប្រតិបត្តិទៅមន្ទីរសុខាភិបាលខេត្ត-ក្រុង ឱ្យមានប្រសិទ្ធភាព ។

**ប្រការ ១២:** បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះត្រូវបានចាត់ទុកជានិរាករណ៍ ។

ប្រកាសនេះចាប់ផ្តើមមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ក្រសួងសុខាភិបាល

នុត_សុខុម

**ចំលងជូន :**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- សាលាខេត្ត-ក្រុង-ស្រុក ទូទាំងប្រទេស
- អង្គភាពសុខាភិបាលខេត្ត-ក្រុង ទូទាំងប្រទេស
- ឯកសារ